**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
លេខ : ៦០ បទ.សណណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្នើសុំបំពេញប្រតិបត្តិការអាជីវកម្ម ក្នុងវិស័យប្រៃសណីយ៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន តាមប្រព័ន្ធអេឡិចត្រូនិក (e-Registration) សម្រាប់ថ្នាក់ជាតិ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបដល់ប្រតិបត្តិករ ឬម្ចាស់អាជីវកម្មទាំងអស់ មេត្តាជ្រាបថា ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក ការកសាងរដ្ឋាភិបាលឌីជីថលគឺជាកិច្ចការអាទិភាពដែលត្រូវចាប់ផ្តើមធ្វើបរិវត្តកម្មឌីជីថល ដោយផ្តោតលើការពង្រឹងសេវាសាធារណៈតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាស្នូល សំដៅជំរុញការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ក្នុងន័យនេះ ក្រសួងបានបង្កើតនូវប្រព័ន្ធស្នើសុំបំពេញប្រតិបត្តិការអាជីវកម្មសម្រាប់ថ្នាក់ជាតិ ដែលមានឈ្មោះថា «**ប្រព័ន្ធ e-Registration**»។ ប្រព័ន្ធនេះ នឹងផ្តល់ភាពងាយស្រួល និងឆាប់រហ័ស ដល់ប្រតិបត្តិករ ឬម្ចាស់អាជីវកម្មក្នុងការស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ សម្រាប់បំពេញប្រតិបត្តិការអាជីវកម្មក្នុងវិស័យប្រៃសណីយ៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ ប្រតិបត្តិករ ឬម្ចាស់អាជីវកម្ម អាចដាក់ពាក្យស្នើសុំ តាមរយៈគេហទំព័រ service.mptc.gov.kh និងសូមស្កេន QR Code ខាងក្រោម ដើម្បីទាញយកសៀវភៅណែនាំអំពីការប្រើប្រាស់ប្រព័ន្ធ e-Registration នេះ។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមណែនាំក៏ដូចជាលើកទឹកចិត្តឱ្យប្រតិបត្តិករ ឬម្ចាស់អាជីវកម្មទាំងអស់ចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធ e-Registration ដើម្បីជាជំនួយដល់ការស្នើសុំបំពេញប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ហើយក្រសួងរីករាយនឹងទទួលមតិយោបល់ត្រលប់ពីប្រតិបត្តិករ ឬម្ចាស់អាជីវកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធនេះ។

សម្រាប់ព័ត៌មានបន្ថែមទាក់ទងទៅនឹងបច្ចេកទេសនៃការប្រើប្រាស់ លោកអ្នកអាចធ្វើការទំនាក់ទំនងតាមរយៈលេខទូរសព្ទ ០២៣ ៧២៤ ៩១១ (សម្រាប់វិស័យប្រៃសណីយ៍) និង ០២៣ ៧២៣ ០៨៣ (សម្រាប់វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន) នៅរៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូម ប្រតិបត្តិករ ឬម្ចាស់អាជីវកម្មទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១

សៀវភៅណែនាំអំពីការប្រើប្រាស់ប្រព័ន្ធ e-Registration

អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.mptc.gov.kh
ទូរសព្ទ : (៨៥៥) ២៣ ៧២៤ ៨១០
ទូរសារ : (៨៥៥) ២៣ ៧២៤ ០៦៩
អ៊ីម៉ែល : info@mptc.gov.kh